ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៣៧
ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨
សាលដីកា
លេខ ២៣ "II"
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

**សាលដីកា**

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកស្រី [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ១៩៦ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉េន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រIV "អ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

- **ជនជាប់ចោទ** ៖ ឈ្មោះ [redacted] សារ៉េន ហៅ ប៊ិន ភេទប្រុស អាយុ ២៤ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅភូមិកណ្ដាល ឃុំគោកព្រីង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះជួល [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន។ (អ្នកប្ដឹងសាទុក្ខ)

-មានលោកស្រី [redacted] សុវ៉ន ជាមេធាវីការពារ



Scanned with CamScanner

- **ជាប់ចោទពីបទ** ចាប់ ឃុំឃាំង និងបង្ខាំងមនុស្សដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវលំ ក្រុមទី៣ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ។

- **ដើមបណ្ដឹងរដ្ឋប្បវេណី៖** ឈ្មោះ [redacted] ចន្នី ភេទស្រី អាយុ ៤៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះជួល ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង០៧:៣០នាទី ជនល្មើសឈ្មោះ [redacted] សារ៉េន ហៅ ប៊ិន បានមកនាំជនរងគ្រោះឈ្មោះ [redacted] សារី នៅផ្ទះស្ថិតនៅភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យនៅហាងលក់កាហ្វេស្ថិតនៅភូមិទ្រា៣ សង្កាត់ស្ទឹងមានជ័យ ដោយប្រាប់ថាបងឱ្យហៅហើយ ជនល្មើសបានសួររកលេខទូរស័ព្ទម្ដាយរួចក៏ប្រើទូរស័ព្ទសាធារណៈ ដោយផ្លាស់ប្ដូរជាច្រើនកន្លែងទៅគម្រាបឈ្មោះ [redacted] ចន្នី ត្រូវជាម្ដាយជនរងគ្រោះឱ្យយកប្រាក់ចំនួន ៣.០០០ ដុល្លារអាមេរិក ដោយណាត់ជួបប្រគល់ប្រាក់នៅធនាគារអេស៊ីលីដាក្បែរគល់ស្ពានស្ទឹងមានជ័យក្នុងសង្កាត់បឹងសាឡាងនៅ វេលម៉ោង១២:០០ នាថ្ងៃខែឆ្នាំដដែល លុះដល់ពេលកំណត់ក្រុមគ្រួសារជនរងគ្រោះបានយកប្រាក់ទៅប្រគល់ឱ្យជនល្មើស ក្នុងពេលនោះអ្នកជិតខាងបានឃើញជនរងគ្រោះក៏នាំទៅផ្ទះក្រុមគ្រួសារជនរងគ្រោះក៏ត្រលប់ទៅផ្ទះវិញ បន្ទាប់មកជនល្មើសបានត្រលប់មកយកជនរងគ្រោះនៅហាងលក់កាហ្វេ ក៏ត្រូវនគរបាលប៉ុស្ដិ៍ស្ទឹងមានជ័យឃាត់ខ្លួនតែម្ដង។

សាលាដំបូងខេត្តសៀមរាប បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៦៦ ក្រ១ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ ដែលមានខ្លឹមសារ នៃសេចក្ដីសម្រេចដូចតទៅ ៖

១.ផ្ដន្ទាទោស ឈ្មោះ [redacted] សារ៉េន ហៅ ប៊ិន ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល១៥ឆ្នាំ "ដប់ប្រាំឆ្នាំ" ពីបទ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ( ស្ថានទម្ងន់ទោស) ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវលំ ក្រុមទី៣ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា២៥៤ នៃក្រមព្រហ្មទណ្ឌ។

២.សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារ៉េន ហៅ ប៊ិន មេធាវីការពារជនជាប់ចោទ ម្ដាយជនរងគ្រោះ ជនរងគ្រោះ បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

សាលក្រមនេះត្រូវបានឈ្មោះ [redacted] សារ៉េន ហៅ ប៊ិន ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ ៤៥៦ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រIV "អ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ដែលមានខ្លឹមសារ នៃសេចក្ដីសម្រេចដូចតទៅ ៖

Scanned with CamScanner

១.ទទួលបណ្ដឹងឧទ្ធរណ៍លេខ៨៥៦ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១ របស់ជនជាប់ចោទ [redacted] សារ៉េន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់គតិច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៦៦ក្រ១ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី។

៤.សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ។ បើកសិទ្ធិប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

សាលដីកានេះត្រូវបានឈ្មោះ [redacted] សារ៉េន ប្ដឹងសាទុក្ខតាមបណ្ដឹងលេខ ១៩៦ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានថា ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ដែលតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល គឺមានសំអាងហេតុ និងភស្តុតាងត្រឹមត្រូវតាមច្បាប់ ព្រោះថា អំពើប្រព្រឹត្តបទល្មើស គឺជាបទល្មើសជាក់ស្ដែង ពោលគឺសមត្ថកិច្ចចាប់ខ្លួនពេលកំពុងប្រព្រឹត្តបទល្មើស។ ម្យ៉ាងជនជាប់ចោទ បានសារភាពអំពើប្រព្រឹត្តរបស់ខ្លួន ដែលស៊ីសង្វាក់ទៅនឹងចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ដែលទំនាក់ទំនងតាមទូរស័ព្ទជាមួយគ្នា ដូចមានក្នុងសំអាងហេតុចំណុចទី២ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់។ ការបដិសេធថាខ្លួនគាត់តែនិយាយជាមួយម្ដាយជនរងគ្រោះ គ្រាន់តែជាចម្លើយដោះសារប៉ុណ្ណោះ។ ដូច្នេះតំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រIV "អ" ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

- ជនជាប់ចោទឈ្មោះ [redacted] សារ៉េន បានឆ្លើយថា មូលហេតុដែលខ្លួនមិនសុខចិត្តគឺដោយសារតែសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាសាលាឧទ្ធរណ៍ បានកំណត់ផ្ដន្ទាទោសរូបខ្លួន ១៥ឆ្នាំ គឺច្រើនពេក ដោយសារបទល្មើសនេះខ្លួនបានឆ្លើយសារភាព និងទទួលស្គាល់ពីកំហុស ដែលខ្លួនបានប្រព្រឹត្ត ហើយពាក្យថា ចាប់ឃុំឃាំងមនុស្សដោយខុសច្បាប់ គឺខ្លួនមិនបានឃុំឃាំងមនុស្សទុកនោះទេ ពេលដែលមន្ត្រីនគរបាលចុះមកឃាត់ខ្លួនគឺនៅទីសារធារណៈ (ហាងកាហ្វេ) ហើយជនរងគ្រោះគាត់បានត្រលប់ទៅផ្ទះរួចហើយ។ ជាចុងក្រោយខ្លួនសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង។

- លោកស្រីមេធាវី [redacted] ស៊ីវ៉ែន បានធ្វើសេចក្ដីសន្និដ្ឋានការពារជនជាប់ចោទថា ក្រោយពីបានសិក្សាលើសំណុំរឿង និងឆ្លងតាមការសួរដេញដោល ពេលនេះយើងឃើញថា អំពើរបស់ [redacted] សារ៉េន គឺជាអំពើមួយអចេតនា ឃើញថាគាត់មិនមានចេតនា ទុច្ចរិតពីដំបូងថាចាប់ក្មេង ដើម្បីជំរិតទារប្រាក់នោះទេ។ អង្គហេតុដំបូងឡើយគឺ [redacted] សារ៉េន គាត់ជំពាក់លុយម្ដាយជនរងគ្រោះចំនួនតែ ២ម៉ឺនរៀល តែប៉ុណ្ណោះ ហើយនៅថ្ងៃ



Scanned with CamScanner

កើតហេតុនោះគឺ [redacted] សារ៉េន មានបំណងយកលុយដែលជំពាក់នោះមកសងម្តាយជនរងគ្រោះ ប៉ុន្តែចៃដន្យអី នៅពេលគាត់មកដល់ផ្ទះម្តាយជនរងគ្រោះ ពេលនោះម្តាយជនរងគ្រោះមិនមានវត្តមាននៅផ្ទះនោះទេ គឺ ឃើញតែជនរងគ្រោះ ដែលជាក្មេងអាយុក្រោម ១០ឆ្នាំ ហើយ [redacted] សារ៉េន គិតថាក្មេងនៅផ្ទះតែម្នាក់ឯង ហើយម្តាយមិននៅគាត់ខ្លាចថាក្មេងកើតរឿងអីក៏បានហៅម៉ូតូឌុបក្មេងមកជាមួយ ហើយបានទិញបាយ ទិញ ទឹកឱ្យហូបជម្មតា គឺក្នុងគោលបំណង សុចរិតទេ។ ចំពោះគេទូរសព្ទ័ទៅទារលុយម្តាយជនរងគ្រោះចំនួន ៣.០០០ ដុល្លានោះ គឺគាត់បានសារភាពហើយថា គាត់បានតេទៅមែន ក៏ប៉ុន្តែគោលបំណងនិយាយលេង ទេ។ ក្នុងនាមខ្លួនជាមេធាវីការពារជនជាប់ចោទ ខ្លួនសំនូមពរសុំឱ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងតំណាង មហាអយ្យការ មេត្តាពិចារណាពាក់ពន្ធ ទណ្ឌកម្មមកលើជនជាប់ចោទដែលគាត់មិនមានចេតនាទុច្ចរិតក្នុង ការប្រព្រឹត្ត មួយវិញទៀតមិនបានយល់អំពីច្បាប់ថា អំពើដែលគាត់ធ្វើគឺ ខុសនឹងច្បាប់ធ្ងន់ធ្ងរនោះទេ។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៩៦ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ របស់ជនជាប់ចោទ [redacted] សារ៉េន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧, ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេច តម្កល់សាលក្រមព្រហ្មទណ្ឌ របស់សាលាដំបូង រាជធានីភ្នំពេញ ទុកជាបានការ ដោយប្រកាសពិរុទ្ធភាព និងផ្តន្ទាទោសជនជាប់ចោទ ប៊ូ សារ៉េន ពីបទ ចាប់ ឃុំ ឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស តាមមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌនោះ ជាការត្រឹម ត្រូវហើយ ព្រោះថាជនជាប់ចោទ [redacted] សារ៉េន ត្រូវបានចាប់ខ្លួននៅពេលកំពុងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ ស្តែង ហើយជនជាប់ចោទនេះបានឆ្លើយសារភាពរួចហើយនៅនគរបាលយុត្តិធម៌ បង្ហាញច្បាស់លាស់អំពី សកម្មភាពដែលខ្លួនប្រព្រឹត្ត។ ចម្លើយសារភាពរបស់ជនជាប់ចោទនេះ បានបង្ហាញអង្គហេតុដែលមានលក្ខណៈ ស៊ីសង្វាក់គ្នាទាំងស្រុង ជាមួយនឹងចម្លើយរបស់ជនរងគ្រោះ ម្តាយ និងបងស្រីរបស់ជនរងគ្រោះ ព្រមទាំង សាក្សីម្នាក់ៗ ដែលបានឃើញសកម្មភាពរបស់ជនជាប់ចោទផ្ទាល់។ ទោះបីជនជាប់ចោទបានកែប្រែចម្លើយ របស់ខ្លួននៅចំពោះមុខតុលាការថា ជាការលេងសើចជាមួយម្តាយរបស់ជនរងគ្រោះក្តី ក៏មិនអាចទទួលយក ចម្លើយនេះបានដែរ ព្រោះថាជាការមិនទំនង និងមិនសមហេតុផលសោះឡើយ។ ដោយពុំមានកស្តុតាងផ្ទុយ ហើយក៏ជាបទល្មើសព្រហ្មទណ្ឌជាក់ស្តែងផងនោះ យោងតាមមាត្រា ១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ



Scanned with CamScanner

កស្តុតាងដាក់បន្ទុកលើជនជាប់ចោទនេះ មានគ្រប់គ្រាន់ហើយ។ រីឯការផ្តន្ទាទោសជនជាប់ចោទ [redacted] សារ៉េន ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ ដែលជាកម្រិតទណ្ឌកម្មអប្បបរមានៃទណ្ឌកម្មចែងក្នុងបទប្បញ្ញត្តិមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌនោះ បានបង្ហាញថា ជនជាប់ចោទនេះត្រូវបានតុលាការលើកយកស្ថានសម្រាលទោសមកពិចារណា និងបានផ្តល់ស្ថានសម្រាលទោសឱ្យរួចហើយ។

៣-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ [redacted] សារ៉េន មិនមានមូលហេតុត្រឹមត្រូវ ស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រIV "អ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ដែលសម្រេចសេចក្តីមកនេះ ត្រឹមត្រូវហើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៩៦ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ របស់ជនជាប់ចោទ [redacted] សារ៉េន ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧២ ក្រIV "អ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទុកជាបានការ ។

*សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។*



Scanned with CamScanner